អន្តរប្រិយ៍
សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ
## ក្រោមប្រធានបទ អត្ថន័យវិជ្ជាផ្លូវលោក និងវិជ្ជាផ្លូវធម៌

website: www.hoksavann.org

ថ្ងៃទី២១ កុម្ភៈ ២០០៨



វិជ្ជាផ្លូវលោក បានដល់វិជ្ជាគ្រប់យ៉ាងដែលមនុស្សបង្កើតឡើង តាមការត្រិះរិះឬពិសោធន៍ធម្មតា មានការពិតទៅតាមលោកកិយសច្ចៈ ដូចជាចំណេះខាងវិជ្ជាពេទ្យ ខាងអក្សរសាស្ត្រ ខាងទស្សនវិជ្ជា ខាងបច្ចេកទេស វិទ្យាសាស្ត្រផ្សេងៗជាដើម ។ វិជ្ជាទាំងនេះ អាចយកទៅបំរើនិងសម្រួលជីវភាពរបស់មនុស្សនិងសង្គមមនុស្សបានយ៉ាងប្រសើរណាស់ បើគេយកទៅប្រើក្នុងផ្លូវត្រូវប្រកបដោយសីលធម៌ ។ វិជ្ជារបស់វិទ្យាសាស្ត្រមួយផ្នែកទៀត ធ្វើឲ្យសង្គមមនុស្សមានសេចក្ដីអន្តរាយ គឺការបង្កើតគ្រឿងសាស្ត្រាវុធ តើការបង្កើតអាវុធដើម្បីអ្វី ? គឺពិតជាយកទៅសម្លាប់គ្នា ។ វិជ្ជាផ្លូវលោកអាចជួយសម្រួលការរស់នៅរបស់មនុស្សឲ្យបានសុខស្រួលបានខ្លះ ប៉ុន្តែពុំអាចកំចាត់សេចក្ដីទុក្ខឲ្យអស់ដោយដាច់ខាតបានឡើយ ព្រោះបញ្ហាចាស់ឈឺស្លាប់ បញ្ហាព្រាត់ប្រាស់គ្នា វិជ្ជាផ្លូវលោកពុំអាចដោះស្រាយបានឡើយ ។ អ្នកចេះដឹងផ្លូវលោកផ្នែកណាមួយ ទុកជាការប្រសើរមួយហើយ សំរាប់ដោះស្រាយបញ្ហាសង្គមមនុស្ស ប៉ុន្តែអស់លោកទាំងនោះនៅមានអវិជ្ជានៅឡើយ អវិជ្ជាព្រោះពុំដឹងសច្ចធម៌ តាមវិជ្ជាផ្លូវធម៌របស់ព្រះពុទ្ធសាសនា ដែលជាវិជ្ជាធ្វើទុក្ខឲ្យអស់ទៅបាន គឺវិជ្ជាក្នុងខន្ធប្រាំមានរូបខន្ធជាដើម ដែលជាអនិច្ចំ ទុក្ខំ និងអនត្តា ។ វិជ្ជាផ្លូវលោកពុំអាចកំចាត់បង់កិលេសតណ្ហា អវិជ្ជា ដែលជាហេតុបច្ច័យនាំកើតខន្ធប្រាំបានឡើយ ។ មួយទៀតសេចក្ដីសុខ ពុំមែនកើតឡើងតែពីគ្រឿងសម្ភារៈប៉ុណ្ណោះទេ ប៉ុន្តែត្រូវកើតមកពីផ្លូវចិត្តផង គឺចិត្តស្ងប់មិនលោភ មិនក្រោធ មិនវង្វេង ។ ពាក្យខ្មែរក៏មាននិយាយថា សុខកាយសប្បាយចិត្ត ។ បើសុខកាយមានសម្ភារៈ បរិភោគ ប្រើប្រាស់ និងកាយមិនមានរោគ ប៉ុន្តែចិត្តពុំសប្បាយដោយមានវិបត្តិអ្វីមួយ មនុស្សនោះពុំអាចមានសុភមង្គលឡើយ ។ ដូច្នេះវិជ្ជាផ្លូវលោក ពុំអាច

ដោះស្រាយបញ្ហាទុក្ខផ្លូវចិត្តបានឡើយ ។

ចំណែកវិជ្ជាផ្លូវធម៌របស់ព្រះពុទ្ធសាសនា ជាវិជ្ជាធ្វើឲ្យអ្នកប្រតិបត្តិអស់ទុក្ខ ។ អ្នករកឃើញវិជ្ជាផ្លូវធម៌ គឺព្រះសម្មាសម្ពុទ្ធ ព្រះអង្គមានប្រះទ័យបរិសុទ្ធ ទើបឃើញការពិតនោះ ដែលផ្ទុយគ្នាពីអ្នករកឃើញវិជ្ជាផ្លូវលោក ដែលមិនមានចិត្តបរិសុទ្ធ ពុំអាចឃើញសច្ចធម៌ ដែលជាផ្លូវប្រតិបត្តិដើម្បីកំចាត់ទុក្ខបានឡើយ ។ វិជ្ជាផ្លូវធម៌ជាបរមត្ថវិជ្ជា ជាវិជ្ជាមានសេចក្តីដ៏ជ្រាលជ្រៅ ដែលជាវិជ្ជាមានបញ្ញត្តិ ។ ពាក្យថាវិជ្ជាមានបញ្ញត្តិ គឺបញ្ញត្តិ ឬដាក់ឈ្មោះត្រូវទៅតាមការពិត ដូចពាក្យបញ្ញត្តិជារូប ប្រែថាធម្មជាតិដែលកើតឡើងហើយវិនាសទៅវិញ ដោយក្តៅនិងត្រជាក់ជាដើមហៅថារូប ។ បញ្ញត្តិថាវេទនា ប្រែថាធម្មជាតិដែលដឹង ឬទទួលសោយអារម្មណ៍ជាសុខជាទុក្ខ ហៅថាវេទនា ។ ចំណែកអវិជ្ជាមានបញ្ញត្តិ ដែលវិជ្ជាផ្លូវលោកដាក់ឈ្មោះ ឬបញ្ញត្តិឡើង មិនត្រឹមត្រូវតាមការពិតឡើយ ជាលោកិយសច្ចៈ ដូចជាឈ្មោះដើមឈើ ឈ្មោះសត្វ ឈ្មោះមនុស្ស ។ គេដាក់ឈ្មោះ ឬបញ្ញត្តិឡើងដើម្បីកុំឲ្យច្រឡំគ្នា ពុំមែនការពិតនៅក្នុងឈ្មោះនោះឡើយ ដូចជាមនុស្សឈ្មោះរស់ ពុំមែនមនុស្សនោះរស់រហូតមិនស្លាប់ឡើយ ក៏ដូចមនុស្សឈ្មោះជា ពុំមែនមនុស្សនោះពុំឈឺឡើយ នេះជាលោកិយសច្ចៈ ។ វិជ្ជាផ្លូវលោកខ្លះ ធ្វើឲ្យមនុស្សសម្លាប់គ្នា ដូចទស្សនវិជ្ជារបស់កាល់ម៉ាក មេទ្រីស្តិកុម្មុយនិស្ត ដែលលោកឡេនីនយកមកអនុវត្តចេញជាកុម្មុយនិស្តឆ្នាំ១៩១៧ ហើយបន្តមកម៉ៅ-សេទុងនៃចិនកុម្មុយនិស្ត ធ្វើឲ្យមនុស្សចងកំហឹងនឹងគ្នា សម្លាប់គ្នាអស់រាប់រយលាននាក់ រហូតដល់វាលពិឃាតខ្មែរក្រហម ដែលផ្ទុយពីវិជ្ជាផ្លូវធម៌របស់ព្រះពុទ្ធ ជាធម៌អហឹង្សាការមិនបៀតបៀន ដែលជាមូលដ្ឋាននៃសុខសន្តិភាពពិភពលោក ។ មគ្គប្រកបដោយអង្គ៨ មានសម្មាទិដ្ឋិ ការយល់ត្រូវជាដើម សម្មាសមាធិការដំកល់ចិត្តឲ្យនៅនឹងត្រូវជាទីបំផុត ជាផ្លូវប្រតិបត្តិទៅកាន់ការរំលត់ទុក្ខ ។ ផ្លូវប្រតិបត្តិនេះ បើរួមឲ្យខ្លីមានបីគឺ ទាន សីល ភាវនា សំរាប់ពុទ្ធបរិស័ទជាគ្រហស្ថប្រតិបត្តិ និងសីលសមាធិបញ្ញាសំរាប់ព្រះសង្ឃប្រតិបត្តិ ។ ផ្លូវប្រតិបត្តិនេះ គ្មានតាបសឥសីលទ្ធិសាសនាទស្សនវិទូណារកឃើញឡើយ ។ លទ្ធិសាសនាដទៃតែងប្រព្រឹត្តខុស ដូចធ្វើតមៈឃោគៈ ការធ្វើបាបកាយ, ផ្លូវប្រតិបត្តិនេះព្រះអង្គច្រានចោល និងផ្លូវមួយទៀត, គឺចិត្តត្រេកអរនឹងកាមគុណ៥, ក៏ព្រះអង្គច្រានចោល, ព្រោះជាផ្លូវមិនអាចត្រាស់ដឹងឃើញអរិយសច្ច៤ មានទុក្ខសច្ចជាដើម ដើម្បីរំលត់ទុក្ខបាន ។ មគ្គប្រកបដោយអង្គ៨នេះ ជាមជ្ឈិមា បដិបទា ជាផ្លូវប្រតិបត្តិជាកណ្តាល ដោយឃើញទោសផ្លូវប្រតិបត្តិអមខាងទាំងពីរនេះឯង ។ កាលណាប្រតិបត្តិតាមមគ្គប្រកបដោយអង្គ៨, ទើបឃើញទោសក្នុងខន្ធ៥ ដែលប្រព្រឹត្តទៅជាអនិច្ចំ ទុក្ខំ និងអនត្តាត្រូវកំណត់ដឹង, នេះតណ្ហា, ធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។ ព្រះអរហន្តទាំងឡាយមានព្រះពុទ្ធជាដើមបានដល់ត្រើយគឺព្រះនិព្វានជាការរំលត់ទុក្ខ ឈប់វិលកើតវិលស្លាប់ក្នុងសង្សារវដ្តទៀតហើយ ។ អ្នកចេះ

វិជ្ជាធម៌ ហើយខំប្រឹងប្រែងប្រតិបត្តិឲ្យបានម៉ត់ចត់ នឹងដល់ការរំលត់ទុក្ខ ។ ដូច្នេះ អ្នកមានវិជ្ជាផ្លូវលោក ត្រូវសិក្សានិងប្រតិបត្តិតាមផ្លូវធម៌ផង ទើបដល់នូវការរំលត់ទុក្ខដោយដាច់ខាត ។៚